# ព្រះរាជក្រម

នស/រកម/១២០៦/០៣៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន

**មាត្រា ១.—**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន ដែលធ្វើនៅទីក្រុងវីយ៉ែន ប្រទេសអូទ្រីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៥ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.—**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បញ្ជាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរស.០៦១២.៥៣៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខៈ ៤៨៥ ច.ល

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១ អធិការ.ឧបខ

# សេចក្តីថ្លែងហេតុ

# នៃសេចក្តីព្រាងច្បាប់

# ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែន

# ស្តីពីកិច្ចការពារស្រទាប់អូហ្សូន

ស្រទាប់អូហ្សូនត្រូវបានគេរកឃើញស្ថិតនៅចន្លោះបរិយាកាសរវាង ១០ទៅ១៥ គីឡូម៉ែត្រពីផែនដីដែលវាមានសារប្រយោជន៍សំខាន់ណាស់ក្នុងការការពារខ្លួនយើងពីការប៉ះពាល់ដោយកាំរស្មីពណ៌ស្វាយ (UV) នៃពន្លឺព្រះអាទិត្យ ។ ការធ្លុះធ្លាយស្រទាប់អូហ្សូននឹងធ្វើឱ្យមានការកើនឡើងកាំរស្មីពណ៌ស្វាយមកលើផែនដីយើងដែលនឹងធ្វើឱ្យប៉ះពាល់មកលើស្បែក និងប្រព័ន្ធការពាររាងកាយរបស់យើងព្រមទាំងមានឥទ្ធិពលអាក្រក់ដល់ភ្នែក រុក្ខជាតិ សត្វ និងវត្ថុធាតុប្លាស្ទិកទាំងឡាយ ។

នៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ ការធ្លុះធ្លាយនូវស្រទាប់អូហ្សូន បានធ្វើឱ្យពិភពលោក មានការចាប់អារម្មណ៍ និងព្រួយបារម្ភខ្លាំង។ មូលហេតុចម្បងនៃការធ្លុះធ្លាយនោះ គឺត្រូវបានគេរកឃើញថា បណ្តាលមកពីការបំផ្លាញ ដោយសារសារធាតុក្លរ៉ូ-ភ្លុយអរ៉ូកាបូន Chlorofluorocarbons (CFCs) ។ សារធាតុនេះត្រូវបាន គេរកឃើញ និងប្រើប្រាស់នៅឆ្នាំ១៩២៨ ជាសារធាតុដែលធ្វើឱ្យត្រជាក់ក្នុងម៉ាស៊ីនត្រជាក់ ជាសារធាតុរំលាយ ជាសារធាតុពន្លត់អគ្គីភ័យ។ល។ សារធាតុក្លរ៉ូ-ភ្លុយអរ៉ូកាបូន អាចមានអាយុកាលដ៏វែង ហើយងាយនឹងសាយភាយ ក្នុងរយៈចម្ងាយដ៏ឆ្ងាយឆ្ពោះទៅរកស្រទាប់អូហ្សូននៃបរិយាកាសដែលនៅទីនោះសារធាតុក្លរ៉ូ-ភ្លុយអរ៉ូកាបូន បានធ្វើប្រតិកម្មបំផ្លាញស្រទាប់អូហ្សូន។ ការបាត់បង់ស្រទាប់អូហ្សូន ត្រូវបានគេរកឃើញនៅតំបន់អង់តាក់ទិកនាឆ្នាំ១៩៨៥ ដែលតាំងពីនោះមក ការបាត់បង់នេះ ត្រូវបានគេរកឃើញនៅក្នុងរយៈកម្ពស់មធ្យម និងរយៈកម្ពស់ខ្ពស់នៃស្រទាប់បរិយាកាស ។

បច្ចុប្បន្ននេះ ស្រទាប់អូហ្សូននៃបរិយាកាសកំពុងតែមាននិន្នាការផ្លាស់ប្តូរទៅរកការអន្តរាយយ៉ាងធ្ងន់ធ្ងរដោយសារតែសកម្មភាពរបស់មនុស្សបង្កឡើង។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ផលវិបាកដ៏ធំបំផុត ដែលកើតចេញពីការបំផ្លាញស្រទាប់អូហ្សូន គឺភាពមិនប្រក្រតីនៃការប្រែប្រួលអាកាសធាតុលើភពផែនដី ដែលវាជះឥទ្ធិពលជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើសុខភាពមនុស្ស ហើយបានបង្កឱ្យមានការខូចខាតយ៉ាងខ្លាំងដល់ផលិតភាពរបស់ប្រព័ន្ធធម្មជាតិ ប្រព័ន្ធសង្គម ព្រមទាំងកត្តារូបវ័ន្តផ្សេងៗទៀតដែលបម្រើជាប្រយោជន៍សម្រាប់មនុស្សជាតិ ។ និន្នាការនេះកំពុងត្រូវបានតាមដាន និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ពីសំណាក់អ្នកឯកទេសវិទ្យាសាស្ត្រផ្នែកបរិស្ថានពិភពលោក ដើម្បីដាក់ចេញនូវវិធានការជាបន្ទាន់នានា ក្នុងទិសដៅកាត់បន្ថយ និងឈានទៅបំបាត់ចោលការប្រើប្រាស់សារធាតុ ដែលបំផ្លាញស្រទាប់អូហ្សូននៅក្នុងពេលអនាគត ។

ដោយពិនិត្យឃើញនូវផលលំបាកនៃការបាត់បង់នូវស្រទាប់អូហ្សូនដោយសកម្មភាពរបស់មនុស្ស អង្គការកម្មវិធីបរិស្ថាន សហប្រជាជាតិបានផ្តួចផ្តើមរៀបចំសេចក្តីព្រាងអនុសញ្ញាការពារស្រទាប់អូហ្សូននាឆ្នាំ១៩៧៧ហើយដែលត្រូវបានបណ្តាប្រទេសនៅលើពិភពលោកបានចូលរួមពិភាក្សា និងអនុម័តលើសេចក្តីព្រាងនោះនៅទីក្រុងវីយែនឆ្នាំ១៩៨៥។ តាមរយៈអនុសញ្ញាវីយែនស្តីពីការការពារស្រទាប់អូហ្សូន បានសហការជួយគ្នាទៅវិញទៅមកក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីពង្រីកការយល់ដឹងពីដំណើរការវិវត្តរបស់បរិយាកាស ។

ដើម្បីជំរុញកាត់បន្ថយសារធាតុបំផ្លាញស្រទាប់អូហ្សូន និងការអនុវត្តអនុសញ្ញាវីយែនឱ្យមានប្រសិទ្ធភាព នៅឆ្នាំ១៩៨៧ អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ និងប្រតិភូមកពីប្រទេសជាច្រើនលើពិភពលោក បានមកជួបប្រជុំគ្នានៅទីក្រុងម៉ុងរ៉េអាល់ ដើម្បីអនុម័តពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន។ ដើម្បីជំរុញការអនុវត្តក្នុងការកាត់បន្ថយការសាយភាយសារធាតុបំផ្លាញស្រទាប់អូហ្សូន ពិធីសារម៉ុងរ៉េអាល់ត្រូវបានធ្វើវិសោធនកម្មចំនួន ៤លើកជាបន្តបន្ទាប់រួមមាន :

-វិសោធនកម្មនៅទីក្រុងឡុង ឆ្នាំ ១៩៩០

-វិសោធនកម្មនៅទីក្រុងកូប៉ែនហាហ្គែន ឆ្នាំ ១៩៩២

-វិសោធនកម្មនៅទីក្រុងម៉ុងរ៉េអាល់ ឆ្នាំ ១៩៩៧

-និងវិសោធនកម្មនៅទីក្រុងប៉េកាំង ឆ្នាំ ១៩៩៩ ។

ដោយពិនិត្យឃើញថា កិច្ចការពារស្រទាប់អូហ្សូន ជាកាតព្វកិច្ចរួមដ៏ចាំបាច់របស់ប្រជាពលរដ្ឋទូទាំងពិភពលោក និងដោយឈរលើទស្សនៈថា "**ការការពារស្រទាប់អូហ្សូន គឺជាការការពារអាយុជីវិតមនុស្ស និងបរិស្ថាន**"

មកដល់ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២នេះ មានប្រទេសចំនួន ១៨៤ បានផ្តល់សច្ចាប័នលើអនុសញ្ញាវីយែន និងប្រទេសចំនួន ១៨៣ បានផ្តល់សច្ចាប័នលើពិធីសារម៉ុងរ៉េអាល់រួចហើយ ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាសុំចូលជាសមាជិកនៃអនុសញ្ញាវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូហ្សូនកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ ។ ប៉ុន្តែកម្ពុជាមិនទាន់បានចុះហត្ថលេខាផ្តល់សច្ចាប័នលើវិសោធនកម្មណាមួយក្នុងចំណោមវិសោធនកម្មទាំង ៤ ខាងលើនៅឡើយទេ ។

យោងទៅលើការសិក្សាឯកសារ និងបទពិសោធន៍ពីប្រទេសនានានៅក្នុងតំបន់ ក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាវីយែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន កម្ពុជានឹងទទួលបានសារប្រយោជន៍ដូចខាងក្រោមនេះ :

១-ក្នុងនាមជាសមាជិកនៃអនុសញ្ញា និងពិធីសារនេះប្រទេសកម្ពុជានឹងពុំត្រូវបង់ថវិកា ឬចំណាយណាមួយឡើយ ។

២-ក្នុងនាមជាសមាជិកនៃអនុសញ្ញា និងពិធីសារនេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចចូលរួមជាមួយសហគមអន្តរជាតិ ក្នុងការទប់ស្កាត់នូវការរេចរឹលនៃស្រទាប់អូហ្សូន ដែលបង្កដោយសារធាតុបំផ្លាញ ស្រទាប់អូហ្សូន ដោយកាត់បន្ថយ និងលុបបំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន តាមរយៈការទប់ស្កាត់ និងកាត់បន្ថយការនាំចូល ការប្រើប្រាស់ ការកែច្នៃ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន និងឧបករណ៍ ឬគ្រឿងបរិក្ខាដែលប្រើប្រាស់សារធាតុទាំងនេះ ហើយដែលឧបករណ៍ទាំងនោះ ភាគច្រើនកំពុងត្រូវបានគេស្វះស្វែងរកកន្លែងបោះចោល ពីព្រោះឧបករណ៍ទាំងនោះនឹងត្រូវបញ្ឈប់ឱ្យប្រើប្រាស់តទៅទៀតបន្ទាប់ពីឆ្នាំ២០១០ ខាងមុខនេះ ។

៣-ទទួលផលចំណេញផ្នែកនយោបាយ :

-បង្ហាញពីទស្សនៈ ឆន្ទៈរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថានជាមួយសហគមន៍អន្តរជាតិ ។

-លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំ ដែលរៀបចំឡើងសម្រាប់ពិភាក្សាដោះស្រាយបញ្ហាកាត់បន្ថយសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ។

៤-ទទួលផលចំណេញផ្នែកបរិស្ថាន :

-ក្នុងនាមជាសមាជិកនៃអនុសញ្ញា និងពិធីសារនេះ ប្រទេសកម្ពុជានឹងទទួលបាននូវការកាត់បន្ថយនូវឥទ្ធិពលនៃការកើនកម្តៅដែលធ្វើឱ្យខូចបរិស្ថានធម្មជាតិ និងការប៉ះពាល់លើសុខភាពសាធារណៈដោយសារការ

ធុះធ្លាយស្រទាប់អូហ្សូន ។

-ទទួលបាននូវការគាំទ្រលើជំនួយបច្ចេកទេស ក្នុងការបណ្តុះបណ្តាលការផ្តល់នូវបច្ចេកវិទ្យា និងការទទួលព័ត៌មាន និងជំនួយជាថវិកាសម្រាប់អនុវត្តគម្រោង ដែលទាក់ទងនឹងការអនុវត្តអនុសញ្ញា និងពិធីសារនេះ ដូចជាការកែច្នៃ ការត្រួតពិនិត្យការនាំចូលនូវឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូនប្រកបដោយសុវត្ថិភាព ដែលបច្ចុប្បន្ននេះ យើងទទួលបានជំនួយផ្នែកពង្រឹងសមត្ថភាព និងការរៀបចំធ្វើកម្មវិធីជាតិដើម្បីកាត់បន្ថយ និងលុបបំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ។

៥-ផលចំណេញផ្នែកសេដ្ឋកិច្ច :

-ដោយសារកម្ពុជាយើងមិនមែនជាប្រទេសអ្នកផលិត ឬអ្នកនាំចេញឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ដូច្នេះការចូលជាសមាជិកវានឹងមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់កម្ពុជាយើងទេ

-អាចចូលរួមក្នុងការអនុវត្តគម្រោងផ្នែកការប្រើប្រាស់ឡើងវិញ ការកែច្នៃសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ដែលថវិកាទាំងនេះនឹងទទួលបានពីថវិកាពហុភាគី

-អាចទទួលបានថវិកាក្នុងការរៀបចំប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ក្នុងការត្រួតពិនិត្យការនាំចេញ នាំចូលដោយប្រើប្រព័ន្ធព័ត៌មានវិទ្យាទំនើប ដែលអាចទប់ស្កាត់ចរាចរណ៍ទំនិញខុសច្បាប់បានដោយមានប្រសិទ្ធភាព។

ពិនិត្យជារួម ការចូលជាសមាជិកនៃអនុសញ្ញាវីយែន និងពិធីសារម៉ុងរ៉េអាល់ នឹងពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជាឡើយ។ ផ្ទុយទៅវិញវា គឺជាឱកាសដ៏ល្អមួយដែលអនុញ្ញាតឱ្យកម្ពុជាទទួលបាននូវផលចំណេញលើគ្រប់វិស័យ ដូចបានរៀបរាប់ខាងលើ ដែលជាទុនយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ។

អាស្រ័យសេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូននេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០០៥

ហ៊ុន សែន

# អនុសញ្ញាទីក្រុងវីយែន ស្តីពីកិច្ចការពារស្រទាប់អូសូន ១៩៨៥

(Vienna Convention for the Protection of the Ozone Layer (1985)

ចូលជាធរមានថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៨៨

## បុព្វកថា

ភាគីទាំងអស់នៃអនុសញ្ញានេះ :

ដោយយល់ដឹងច្បាស់ពីឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ ដែលអាចមានទៅលើសុខភាពមនុស្ស និងបរិស្ថាន បណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

ដោយរំលឹកឃើញពីខពាក់ព័ន្ធ ដែលមាននៅក្នុងសេចក្តីប្រកាសរបស់សន្និសីទសហប្រជាជាតិ ស្តីពីបរិស្ថានមនុស្ស ដែលចែងថា "អនុលោមទៅតាមធម្មនុញ្ញរបស់សហប្រជាជាតិ និងគោលការណ៍នានានៃច្បាប់អន្តរជាតិ ប្រទេសទាំងអស់ មានសិទ្ធិមិនអាចប៉ះពាល់បាន ក្នុងការធ្វើអាជីវកម្មលើធនធានរបស់ខ្លួន យោងទៅតាមគោលនយោបាយបរិស្ថានរបស់ខ្លួនផ្ទាល់ និងការទទួលខុសត្រូវ ដើម្បីធានាថា សកម្មភាពនានាដែលស្ថិតនៅក្រោមសិទ្ធិអំណាច ឬការត្រួតត្រារបស់ខ្លួនមិនបណ្តាលឱ្យមានការខូចខាតដល់បរិស្ថានរបស់ប្រទេសផ្សេងទៀត ឬដល់តំបន់ដែលស្ថិតនៅក្រៅសិទ្ធិអំណាចត្រួតត្រារបស់ខ្លួន ។

ដោយគិតគូរពីការណាដល់លក្ខខណ្ឌ និងការទាមទាររបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

ដោយយកចិត្តទុកដាក់ដល់កិច្ចការ និងការសិក្សានានា ដែលធ្វើឡើងនៅក្នុងអង្គការជាតិ និងអន្តរជាតិ ជាពិសេស គឺផែនការសកម្មភាពពិភពលោក ស្តីពីស្រទាប់អូសូនរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ ។

ដោយយកចិត្តទុកដាក់ដល់វិធានការការពារទុកជាមុន ក្នុងកិច្ចការពារស្រទាប់អូសូន ដែលត្រូវបានចាត់រួចហើយ ទាំងនៅថ្នាក់ជាតិ ក៏ដូចជានៅថ្នាក់អន្តរជាតិ ។

ដោយយល់ថា វិធានការការពារស្រទាប់អូសូនពីការកែប្រែដោយសារសកម្មភាពមនុស្ស ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងសកម្មភាពជាអន្តរជាតិ ហើយត្រូវតែផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសត្រឹមត្រូវ ។

ដោយយល់ពីតម្រូវការចាំបាច់នៃការស្រាវជ្រាវបន្តទៀត និងការសង្កេតពិនិត្យជាប្រចាំ ដើម្បីបន្ថែមចំណេះដឹង ស្តីពីស្រទាប់អូសូន និងពីឥទ្ធិពលអវិជ្ជមានដែលអាចកើតមាន បណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

ដោយប្តេជ្ញាចិត្តការពារសុខភាពមនុស្ស និងបរិស្ថាន ប្រឆាំងនឹងឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

បានព្រមព្រៀងគ្នាដូចខាងក្រោម :

## មាត្រា ១
## និយមន័យ

នៅក្នុងអនុសញ្ញានេះ :

១. "ស្រទាប់អូសូន" មានន័យថា ជាស្រទាប់អូសូនបរិយាកាស នៅពីលើស្រទាប់ព្រំប្រទល់របស់ផែនដី ។

២. "ឥទ្ធិពលអវិជ្ជមាន" មានន័យថា ការប្រែប្រួលនៅក្នុងបរិស្ថានរូបសាស្ត្រ ឬបរិស្ថានជីវសាស្ត្រ ដែលរួមទាំងការប្រែប្រួលនៅក្នុងអាកាសធាតុ ដែលមានឥទ្ធិពលបំផ្លិចបំផ្លាញធ្ងន់ធ្ងរលើសុខភាពមនុស្ស ឬលើសមាសភាព ភាពរឹងមាំ និងផលិតភាពរបស់ស្ថានប្រព័ន្ធធម្មជាតិ ឬស្ថានប្រព័ន្ធដែលមនុស្សគ្រប់គ្រង ព្រមទាំងលើសំភារៈដែលមានប្រយោជន៍ដល់មនុស្សជាតិ ។

៣. "បច្ចេកវិទ្យា ឬឧបករណ៍ជំនួស" (alternative technologies or equipment) មានន័យថា បច្ចេកវិទ្យា ឬឧបករណ៍ ដែលការប្រើប្រាស់វា អាចឲ្យគេកាត់បន្ថយ ឬបំបាត់ប្រកបដោយប្រសិទ្ធិភាព នូវការបញ្ចេញចោលសារធាតុនានា ដែលមាន ឬអាចមានឥទ្ធិពលអវិជ្ជមានដល់ស្រទាប់អូសូន ។

៤. "សារធាតុជំនួស" មានន័យថា សារធាតុដែលកាត់បន្ថយ បំបាត់ ឬចៀសវាងឥទ្ធិពលអវិជ្ជមានដល់ស្រទាប់អូសូន ។

៥. "ភាគី" មានន័យថា ភាគី (សមាជិក) នៃអនុសញ្ញានេះ ក្នុងករណីដែលពុំមានការបញ្ជាក់ដោយឡែក ។

៦. "អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់" មានន័យថា អង្គការមួយដែលរួមមានរដ្ឋអធិបតេយ្យនានា នៅតំបន់ណាមួយ ហើយដែលមានសមត្ថកិច្ចនៅក្នុងកិច្ចការទាក់ទងនឹងអនុសញ្ញា ឬពិធីសារនានារបស់អនុសញ្ញានេះ ព្រមទាំងត្រូវបានផ្តល់សិទ្ធិអំណាច យោងតាមនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ក្នុងការចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកនៃលិខិតពាក់ព័ន្ធនានា ។

## មាត្រា ២
## កាតព្វកិច្ចទូទៅ

១. ភាគីទាំងអស់ត្រូវតែចាត់វិធានការសមស្រប យោងទៅតាមខនានារបស់អនុសញ្ញានេះ និងរបស់ពិធីសារទាំងឡាយដែលចូលជាធរមាន ហើយដែលខ្លួនជាសមាជិក សំដៅការពារសុខភាពមនុស្ស និងបរិស្ថាន ប្រឆាំងនឹងឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលមកពី ឬក៏ប្រហែលបណ្តាលមកពីសកម្មភាពមនុស្ស ដែលកែប្រែស្រទាប់អូសូន ។

២. យោងតាមមធ្យោបាយ និងសមត្ថភាពដែលខ្លួនមាន ភាគីទាំងអស់ត្រូវ :

ក. សហប្រតិបត្តិការតាមរយៈការសង្កេតពិនិត្យជាប្រចាំ ការស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មាន សំដៅស្វែងយល់ និងវាយតម្លៃពីឥទ្ធិពលនៃសកម្មភាពមនុស្ស ទៅលើស្រទាប់អូសូន និងពីឥទ្ធិពលទៅលើសុខភាពមនុស្ស និងបរិស្ថាន បណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

ខ. ទទួលយកវិធានការច្បាប់ និងវិធានការរដ្ឋបាលសមស្រប និងសហការក្នុងការសំរបសំរួលគោលនយោបាយសមស្រប សំដៅត្រួតពិនិត្យ ដាក់កំរិត កាត់បន្ថយ ឬបញ្ចៀសនូវសកម្មភាពមនុស្ស ដែលស្ថិតនៅក្រោមសិទ្ធិអំណាច ឬការត្រួតត្រារបស់ខ្លួន ប្រសិនណាបើគេរកឃើញថា សកម្មភាពទាំងនេះមាន ឬក៏ប្រហែលជាមានឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលឲ្យមានការកែប្រែ ឬក៏ប្រហែលជាឲ្យមានការប្រែស្រទាប់អូសូន ។

គ. សហការជាមួយស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ សំដៅអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវអនុសញ្ញានេះ ឬពិធីសារនានានៃអនុសញ្ញានេះ ដែលខ្លួនជាសមាជិក ។

៣. ក្នុងគ្រប់ករណី ខនានានៃអនុសញ្ញានេះមិនអាចប៉ះពាល់ដល់សិទ្ធិរបស់ភាគីនានា ក្នុងការអនុម័តវិធានការក្នុងស្រុក យោងតាមច្បាប់អន្តរជាតិ បន្ថែមលើវិធានការទាំងឡាយដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និងទី ២ ខាងលើ ហើយក៏មិនអាចប៉ះពាល់ដល់វិធានការក្នុងស្រុកបន្ថែម ដែលភាគីណាមួយបានចាត់រួចហើយ ប្រសិនបើវិធានការទាំងនោះស៊ីសង្វាក់គ្នា ជាមួយនឹងកាតព្វកិច្ចរបស់ខ្លួន នៅក្រោមអនុសញ្ញានេះ ។

៤. ការអនុវត្តន៍នូវមាត្រានេះត្រូវតែផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសដ៏សមស្រប ។

## មាត្រា ៣
## ការស្រាវជ្រាវនិងការសង្កេតតាមដានជាប្រចាំ

១. ភាគីទាំងអស់ត្រូវរាប់រងផ្តួចផ្តើមគំនិត និងសហការដោយផ្ទាល់ ឬតាមរយៈស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ ក្នុងការដឹកនាំស្រាវជ្រាវ និងវាយតំលៃវិទ្យាសាស្ត្រលើ :

ក. ដំណើរការរូបសាស្ត្រ ឬគីមី ដែលអាចមានឥទ្ធិពលដល់ស្រទាប់អូសូន ។

ខ. សុខភាពមនុស្ស និងផលប៉ះពាល់ជីវសាស្ត្រផ្សេងទៀត ដែលបណ្តាលមកពីការកែប្រែណាមួយនៃស្រទាប់អូសូន ជាពិសេសផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលនៃកាំរស្មីស្វាយអ៊ុលត្រារបស់ព្រះអាទិត្យ ដែលមានផលប៉ះពាល់ជីវសាស្ត្រ (UV-B) ។

គ. ផលប៉ះពាល់ដល់អាកាសធាតុ ដែលបណ្តាលមកពីការកែប្រែណាមួយនៃស្រទាប់អូសូន ។

ឃ. សារធាតុ ការប្រតិបត្តិ ដំណើរការ និងសកម្មភាពនានា ដែលអាចមានឥទ្ធិពលលើស្រទាប់អូសូន ព្រមទាំងផលប៉ះពាល់សរុបរបស់វា ។

ង. សារធាតុ និងបច្ចេកវិទ្យាជំនួស ។

ច. បញ្ហាសង្គម-សេដ្ឋកិច្ចពាក់ព័ន្ធ ដូចដែលមានចែងលំអិតនៅក្នុងឧបសម្ព័ន្ធទី ១ និងទី ២ ។

២. ភាគីទាំងអស់ត្រូវជំរុញ ឬបង្កើតឱ្យបានសមស្រប ដោយផ្ទាល់ ឬតាមរយៈស្ថាប័នអន្តរជាតិមានសមត្ថកិច្ច និងដោយមានការគិតគូរពេញលេញពីច្បាប់របស់ជាតិ ពីសកម្មភាពកំពុងមានទាំងថ្នាក់ជាតិ និងអន្តរជាតិ នូវកម្មវិធីរួម ឬកម្មវិធីបន្ថែម សំរាប់ការសង្កេតតាមដានជាប្រចាំលើស្ថានភាពស្រទាប់អូសូន និងប៉ារ៉ាម៉ែតពាក់ព័ន្ធផ្សេងទៀត ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ១ ។

៣. ភាគីទាំងអស់ត្រូវសហប្រតិបត្តិការដោយផ្ទាល់ ឬតាមរយៈស្ថាប័នអន្តរជាតិមានសមត្ថកិច្ច ដើម្បីធានាឱ្យមានការប្រមូល ការផ្តល់សុពលភាព និងការបញ្ជូននូវទិន្នន័យស្រាវជ្រាវ ឬទិន្នន័យបានមកពីការសង្កេត តាមរយៈមជ្ឈមណ្ឌលទិន្នន័យពិភពលោកពាក់ព័ន្ធ ដោយទៀងទាត់ និងទាន់ពេលវេលា ។

## មាត្រា ៤
## កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យច្បាប់វិទ្យាសាស្ត្រនិងបច្ចេកទេស

១. ភាគីទាំងអស់ត្រូវសំរបសំរួល និងជំរុញឱ្យមានការផ្លាស់ប្តូរពត៌មានផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស សង្គមសេដ្ឋកិច្ច ពាណិជ្ជកម្ម និងច្បាប់ ដែលពាក់ព័ន្ធនឹងអនុសញ្ញានេះ ដូចមានចែងលំអិតនៅក្នុងឧបសម្ព័ន្ធទី ២ ។ ពត៌មានទាំងនេះត្រូវផ្តល់ឱ្យទៅស្ថាប័ននានា ដែលភាគីទាំងអស់បានឯកភាព ។ នៅពេលទទួលពត៌មានដែលភាគីផ្តល់ឱ្យចាត់ទុកថាជាពត៌មានសំងាត់ ស្ថាប័នទទួលត្រូវធានាថា ពត៌មាននេះនឹងមិនត្រូវបញ្ចេញ ហើយត្រូវសរុបបញ្ចូលគ្នា ដើម្បីការពារភាពសំងាត់របស់វា មុននឹងដាក់ឱ្យភាគីផ្សេងៗយកប្រើប្រាស់ ។

២. ភាគីទាំងអស់ត្រូវសហប្រតិបត្តិការ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងការប្រតិបត្តិរបស់ជាតិខ្លួន ដោយគិតគូរពីតំរូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ផង ក្នុងការជំរុញដោយផ្ទាល់ ឬតាមរយៈស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ នូវការអភិវឌ្ឍន៍ ការផ្ទេរបច្ចេកវិទ្យា និងការផ្ទេរចំណេះដឹង ។ ជាពិសេស កិច្ចសហប្រតិបត្តិការទាំងនេះត្រូវធ្វើឡើងតាមរយៈ :

ក. ការសំរបសំរួលការទទួលយកបច្ចេកវិទ្យា និងឧបករណ៍ជំនួសដោយភាគីដទៃទៀត ។

ខ. ការផ្តល់ឱ្យនូវពត៌មានស្តីពីបច្ចេកវិទ្យា និងឧបករណ៍ជំនួស ព្រមទាំងការផ្គត់ផ្គង់នូវសៀវភៅណែនាំសំរាប់បច្ចេកវិទ្យា ឬឧបករណ៍ទាំងនោះ ។

គ. ការផ្គត់ផ្គង់នូវឧបករណ៍ និងគ្រឿងបរិក្ខារចាំបាច់ សំរាប់ការស្រាវជ្រាវ និងការសង្កេតតាមដានជាប្រចាំ ។

ឃ. ការបណ្តុះបណ្តាលសមស្របសំរាប់បុគ្គលិកបច្ចេកទេស និងវិទ្យាសាស្ត្រ ។

## មាត្រា ៥
## ការបញ្ជូនព័ត៌មាន

តាមរយៈលេខាធិការដ្ឋាន ភាគីទាំងអស់ត្រូវបញ្ជូនឱ្យទៅកិច្ចប្រជុំរបស់ភាគី ដែលបានរៀបចំដោយយោងតាមមាត្រាទី ៦ នូវព័ត៌មានស្តីពីវិធានការនានា ដែលខ្លួនបានចាត់ ដើម្បីអនុវត្តអនុសញ្ញានេះ និងពិធីសារផ្សេងទៀត ដែលខ្លួនបានចុះហត្ថលេខា ក្នុងទំរង់មួយ និងចន្លោះពេលដែលកំណត់ដោយកិច្ចប្រជុំរបស់ភាគី ។

## មាត្រា ៦
## អង្គសន្និបាតរបស់ភាគី

១. អង្គសន្និបាតរបស់ភាគីត្រូវបានបង្កើតឡើង យោងតាមមាត្រានេះ ។ កិច្ចប្រជុំលើកទី ១ នៃអង្គសន្និបាតរបស់ភាគីត្រូវកោះហៅ មិនយឺតជាងមួយឆ្នាំក្រោយពីអនុសញ្ញានេះចូលជាធរមាន ដោយលេខាធិការដ្ឋាន ដែលជ្រើសតាំងជាបណ្តោះអាសន្ន យោងតាមមាត្រាទី ៧ ។ ក្រោយពីពេលនេះមក កិច្ចប្រជុំសាមញ្ញរបស់ភាគីត្រូវប្រព្រឹត្តទៅដោយទៀងទាត់ ក្នុងចន្លោះពេល ដែលនឹងកំណត់ដោយអង្គសន្និបាត នៅក្នុងកិច្ចប្រជុំលើកទី ១ របស់ខ្លួន ។

២. កិច្ចប្រជុំវិសាមញ្ញនៃអង្គសន្និបាតរបស់ភាគី អាចប្រព្រឹត្តទៅនៅពេលណាមួយ ដែលអង្គសន្និបាតយល់ឃើញថាចាំបាច់ ឬនៅពេលដែលមានលិខិតសំណូមពរជាលាយល័ក្ខអក្សរបស់ភាគីណាមួយ ក្នុងករណីដែលមានភាគីដទៃទៀតយ៉ាងហោចណាស់ចំនួនមួយភាគបីគាំទ្រ ក្នុងរយៈពេលប្រាំមួយខែ ក្រោយពេលដែលលេខាធិការដ្ឋានផ្សព្វផ្សាយសំណូមពរនេះទៅឱ្យ ។

អង្គសន្និបាតត្រូវសំរេច និងអនុម័តតាមរយៈកុងសង់ស៊ុស លើបែបបទនីតិវិធី និងបែបបទហិរញ្ញវត្ថុរបស់ខ្លួន និងសំរាប់ស្ថាប័នសាខាដទៃទៀត ក៏ដូចជាលើបែបបទហិរញ្ញវត្ថុសំរាប់ដំណើរការលេខាធិការដ្ឋាន ។

អង្គសន្និបាតត្រូវពិនិត្យជាប្រចាំលើការអនុវត្តន៍នៃអនុសញ្ញានេះ ហើយក្រៅពីនេះត្រូវ:

ក. កំណត់នូវទំរង់ និងរយៈពេលសំរាប់បញ្ជូនព័ត៌មាន ដែលត្រូវធ្វើយោងតាមមាត្រាទី ៥ ព្រមទាំងព័ត៌មាន និងរបាយការណ៍នានា ដែលស្ថាប័នសាខាដាក់ជូន ។

ខ. ពិនិត្យលើព័ត៌មានវិទ្យាសាស្ត្រស្តីពីស្រទាប់អូហ្សូន ពីការកែប្រែស្រទាប់អូហ្សូនដែលអាចកើតមាន និងពីឥទ្ធិពលនៃការកែប្រែនេះ ។

គ. ជំរុញឱ្យមានភាពស៊ីសង្វាក់គ្នា យោងតាមមាត្រាទី ២ នូវគោលនយោបាយសមស្រប យុទ្ធសាស្ត្រ និងវិធានការនានា សំរាប់កាត់បន្ថយការបញ្ចេញចោលនូវសារធាតុ ដែលបណ្តាលឱ្យ ឬដែលអាចបណ្តាលឱ្យមានការកែប្រែស្រទាប់អូហ្សូន ព្រមទាំងផ្តល់នូវអនុសាសន៍លើវិធានការផ្សេងទៀត ទាក់ទងទៅនឹងអនុសញ្ញានេះ ។

ឃ. ទទួលយក ដោយយោងតាមមាត្រាទី ៣ និងទី ៤ នូវកម្មវិធីសំរាប់ការស្រាវជ្រាវ សង្កេតតាមដានជាប្រចាំ កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេស ការផ្លាស់ប្តូរព័ត៌មាន និងការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹង ។

ង. យកមកពិនិត្យ និងទទួលយក នៅពេលដែលមានការទាមទារ យោងតាមមាត្រាទី ៩ និងទី ១០ នូវការធ្វើវិសោធនកម្មនៃអនុសញ្ញានេះ - ព្រមទាំងឧបសម្ព័ន្ធរបស់វា ។

ច. ពិនិត្យពិចារណាលើវិសោធនកម្មនៃពិធីសារណាមួយ ក៏ដូចជាឧបសម្ព័ន្ធរបស់វា ហើយក្នុងករណីនេះ ផ្តល់យោបល់ដល់ភាគីទាំងអស់ ដើម្បីឱ្យទទួលយកនូវវិសោធនកម្មនៃពិធីសារពាក់ព័ន្ធ ។

ឆ. យកមកពិនិត្យ និងទទួលយក នៅពេលដែលមានការទាមទារ យោងតាមមាត្រាទី ១០ នូវឧបសម្ព័ន្ធបន្ថែមរបស់អនុសញ្ញានេះ ។

ជ. យកមកពិនិត្យ និងទទួលយក នៅពេលដែលមានការទាមទារ នូវពិធីសារនានា យោងតាមមាត្រាទី ៨ ។

ឈ. បង្កើតនូវស្ថាប័នសាខានានា ប្រសិនបើមានការចាំបាច់ សំរាប់អនុវត្តន៍អនុសញ្ញានេះ ។

ញ. ស្វែងរក ប្រសិនបើមានការចាំបាច់ នូវសេវារបស់ស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ និងគណៈកម្មាធិការវិទ្យាសាស្ត្រ ដូចជា អង្គការឧតុនិយមពិភពលោក និងអង្គការសុខភាពពិភពលោក ក៏ដូចជាគណៈកម្មាធិការសំរបសំរួលផ្នែកស្រទាប់អូសូន នៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ ការសង្កេតពិនិត្យជាប្រចាំ និងសកម្មភាពផ្សេងទៀត ដែលពាក់ព័ន្ធនឹងគោលបំណងរបស់អនុសញ្ញានេះ ព្រមទាំងប្រើប្រាស់ព័ត៌មានដែលទទួលបានពីស្ថាប័ន និងគណៈកម្មាធិការទាំងនេះឱ្យបានសមស្រប ។

ដ. ពិនិត្យ និងធ្វើសកម្មភាពបន្ថែមទៀត ដែលអាចចាំបាច់ សំរាប់ឈានទៅដល់គោលបំណងនៃអនុសញ្ញានេះ ។

៣. អង្គការសហប្រជាជាតិ ស្ថាប័នជំនាញរបស់អង្គការនេះ និងទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ក៏ដូចជាប្រទេសដែលមិនមែនជាសមាជិករបស់អនុសញ្ញានេះ អាចចូលរួមនៅក្នុងកិច្ចប្រជុំនៃអង្គសន្និបាតរបស់ភាគី ជាអ្នកសង្កេតការណ៍ ។ ស្ថាប័ន ឬទីភ្នាក់ងារណាមួយ ទោះជាថ្នាក់ជាតិ ឬអន្តរជាតិ របស់រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានជំនាញនៅក្នុងវិស័យពាក់ព័ន្ធនឹងកិច្ចការពារស្រទាប់អូសូន ហើយដែលបានជូនដំណឹងដល់លេខាធិការដ្ឋានស្តីពីបំណងរបស់ខ្លួន ក្នុងការចូលរួមក្នុងកិច្ចប្រជុំនៃអង្គសន្និបាតរបស់ភាគី ក្នុងនាមជាអ្នកសង្កេតការណ៍ អាចចូលរួមបាន ប្រសិនណាបើពុំមានការជំទាស់ពីសមាជិកវត្តមានចំនួនយ៉ាងហោចណាស់មួយភាគបី ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវតែអនុលោមទៅតាមបែបបទនីតិវិធី ដែលអនុម័តដោយអង្គសន្និបាតរបស់ភាគី ។

## មាត្រា ៧
## លេខាធិការដ្ឋាន

១. មុខងាររបស់លេខាធិការដ្ឋានរួមមាន :

ក. ចាត់ចែង និងផ្តល់សេវាដល់កិច្ចប្រជុំនានា ដូចមានចែងនៅក្នុងមាត្រាទី ៦, ៨, ៩ និង ១០ ។

ខ. រៀបចំ និងចែកចាយរបាយការណ៍ ដោយផ្អែកទៅលើព័ត៌មានដែលទទួលបាន យោងតាមមាត្រាទី ៤ និង ៥ ក៏ដូចជាព័ត៌មានដែលបានមកពីកិច្ចប្រជុំរបស់ស្ថាប័នសាខានានា ដែលបង្កើតឡើងយោងតាមមាត្រាទី ៦

គ. បំពេញតួនាទីរបស់ខ្លួនដែលកំណត់ដោយពិធីសារណាមួយ ។

ឃ. រៀបចំរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួន ដែលបានធ្វើសំដៅបំពេញមុខងាររបស់ខ្លួន នៅក្រោមអនុសញ្ញានេះ ហើយបង្ហាញរបាយការណ៍ទាំងនេះ ជូនដល់អង្គសន្និបាតរបស់ភាគី ។

ង. ធានាឱ្យមានការសំរបសំរួលចាំបាច់ជាមួយស្ថាប័នអន្តរជាតិពាក់ព័ន្ធ ជាពិសេសធ្វើការរៀបចំផ្នែករដ្ឋបាល ឬកុងត្រានានា ដែលចាំបាច់សំរាប់ការបំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព ។

២. កម្មវិធីបរិស្ថានសហប្រជាជាតិនឹងបំពេញមុខងាររបស់លេខាធិការដ្ឋានជាបណ្តោះអាសន្ន រហូតដល់ពេលចុងកិច្ចប្រជុំអចិន្ត្រៃយ៍លើកទីមួយនៃអង្គសន្និបាតរបស់ភាគី ដែលប្រព្រឹត្តទៅយោងតាមមាត្រាទី ៦ ។ នៅក្នុងកិច្ចប្រជុំអចិន្ត្រៃយ៍លើកទីមួយរបស់ខ្លួន អង្គសន្និបាតរបស់ភាគីត្រូវជ្រើសតាំងលេខាធិការដ្ឋាន ពីចំណោមអង្គការអន្តរជាតិមានសមត្ថកិច្ចដែលមានស្រាប់ ហើយដែលបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការបំពេញមុខងាររបស់លេខាធិការដ្ឋាន ក្រោមអនុសញ្ញានេះ ។

## មាត្រា ៨
## ការអនុម័តពិធីសារ

១. អង្គសន្និបាតរបស់ភាគីអាចអនុម័តលើពិធីសារនានា នៅក្នុងកិច្ចប្រជុំណាមួយ យោងតាមមាត្រាទី ២ ។

២. លេខាធិការដ្ឋានត្រូវផ្ញើអត្ថបទនៃពិធីសារណាមួយដែលស្នើឡើង ជូនទៅសមាជិកទាំងអស់ យ៉ាងហោចណាស់ឱ្យបាន ប្រាំមួយខែ មុនកិច្ចប្រជុំ ។

## មាត្រា ៩
## វិសោធនកម្មនៃអនុសញ្ញាឬពិធីសារ

១. ភាគីនីមួយៗអាចស្នើធ្វើវិសោធនកម្មដល់អនុសញ្ញានេះ ឬពិធីសារណាមួយ ។ វិសោធនកម្មទាំងនេះត្រូវតែឈរលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសត្រឹមត្រូវ ។

២. វិសោធនកម្មនៃអនុសញ្ញានេះត្រូវតែអនុម័តនៅក្នុងកិច្ចប្រជុំនៃសន្និបាតរបស់ភាគី ។ វិសោធនកម្មលើពិធីសារណាមួយត្រូវតែអនុម័តនៅក្នុងកិច្ចប្រជុំរបស់ភាគីនៃពិធីសារនោះ ។ លេខាធិការដ្ឋានត្រូវតែផ្ញើអត្ថបទវិសោធនកម្ម ដែលស្នើឡើងលើអនុសញ្ញា ឬពិធីសារណាមួយ លើកលែងតែក្នុងករណីដែលមានចែងដោយឡែកនៅក្នុងពិធីសារនោះ យ៉ាងហោចណាស់ប្រាំមួយខែ មុនកិច្ចប្រជុំពិនិត្យវិសោធនកម្មនោះ ទៅឱ្យភាគីទាំងអស់ ។ លេខាធិការដ្ឋានក៏ត្រូវផ្ញើសំណើវិសោធនកម្មទៅឱ្យភាគីហត្ថលេខីនៃអនុសញ្ញា ដើម្បីជាពត៌មាន ។

៣. ភាគីទាំងអស់ត្រូវតែខិតខំឱ្យអស់សមត្ថភាព ដើម្បីឈានដល់កិច្ចព្រមព្រៀងលើសំណើវិសោធនកម្មនៃអនុសញ្ញានេះតាមរយៈកុងសង់ស៊ុស ។ ប្រសិនបើកិច្ចខិតខំឱ្យមានកុងសង់ស៊ុសពុំបានសំរេច ហើយពុំអាចឈានដល់កិច្ចព្រមព្រៀងបាន នោះវិសោធនកម្មត្រូវអនុម័តដោយសំលេងភាគច្រើនបីភាគបួនរបស់ភាគីទាំងអស់ ដែលមានវត្តមាន ហើយដែលបោះឆ្នោតនៅក្នុងកិច្ចប្រជុំ ហើយត្រូវដាក់ជូនដល់ភាគីទាំងអស់ សំរាប់ផ្តល់សច្ចាប័ន អនុម័ត ឬការទទួលយក ។

៤. នីតិវិធីដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៣ ត្រូវតែអនុវត្តសំរាប់វិសោធនកម្មនៃពិធីសារទាំងអស់ លើកលែងតែក្នុងករណីដែលពីរភាគបីនៃភាគីរបស់ពិធីសារ ដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំ អនុម័តយល់ស្រប ។

៥. ការផ្តល់សច្ចាប័ន ការអនុម័ត ឬការទទួលស្គាល់លើវិសោធនកម្ម ត្រូវតែផ្ញើជូនដល់កន្លែងតំកល់ជាលាយល័ក្ខអក្សរ ។ វិសោធនកម្មដែលត្រូវបានអនុម័តយោងតាមមាត្រាទី ៣ ឬទី ៤ ត្រូវចូលជាធរមានសំរាប់សមាជិកដែលទទួលស្គាល់ នៅថ្ងៃទី ៩០ ក្រោយពេលដែលកន្លែងតំកល់បានទទួលលិខិតជូនដំណឹងស្តីពីការផ្តល់សច្ចាប័ន ការអនុម័ត ឬការទទួលស្គាល់ របស់សមាជិកនៃអនុសញ្ញានេះយ៉ាងហោចណាស់ចំនួនបីភាគបួន ឬរបស់សមាជិកនៃពិធីសារនេះយ៉ាងហោចណាស់ចំនួនពីរភាគបី លើកលែងតែក្នុងករណីដែលមានចែងដោយឡែកណាមួយនៅក្នុងពិធីសារនេះ ។ វិសោធនកម្មនេះត្រូវចូលជាធរមានសំរាប់សមាជិកទាំងអស់ នៅថ្ងៃទី ៩០ ក្រោយពេលដែលភាគីទាំងនោះតំកល់ទុកនូវឯកសារស្តីពីការផ្តល់សច្ចាប័ន ការអនុម័ត និងការទទួលយកលើវិសោធនកម្មនេះ ។

៦. នៅក្នុងមាត្រានេះ "ភាគីរបស់ពិធីសារ ដែលមានវត្តមាន និងបោះឆ្នោត" មានន័យថា ភាគីដែលមានវត្តមាន និងបោះឆ្នោតយល់ស្រប ឬជំទាស់ ។

## មាត្រា ១០
## ការអនុម័តនិងវិសោធនកម្មលើឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធនានារបស់អនុសញ្ញានេះ ឬរបស់ពិធីសារណាមួយ គឺជាផ្នែកមិនអាចកាត់ផ្តាច់បានរបស់អនុសញ្ញា ឬពិធីសារនោះ ហើយក្នុងករណីដែលអាចមាន សេចក្តីយោងណាមួយទៅលើអនុសញ្ញា ឬពិធីសាររបស់វា គឺជាសេចក្តីយោងទៅលើឧបសម្ព័ន្ធរបស់វាដែរ ។ ឧបសម្ព័ន្ធទាំងនេះនិយាយតែពីកិច្ចការវិទ្យាសាស្ត្រ បច្ចេកទេស និងរដ្ឋបាលប៉ុណ្ណោះ ។

២. លើកលែងតែមានចែងជាពិសេសនៅក្នុងនៅក្នុងពិធីសារណាមួយស្តីពីឧបសម្ព័ន្ធរបស់វា នីតិវិធីដូចខាងក្រោមត្រូវអនុវត្តសំរាប់សំណើ ការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធបន្ថែមរបស់អនុសញ្ញានេះ ឬរបស់ឧបសម្ព័ន្ធទាំងឡាយរបស់ពិធីសារណាមួយ :

ក. ឧបសម្ព័ន្ធសំរាប់អនុសញ្ញានេះត្រូវតែស្នើឡើង និងអនុម័ត យោងទៅតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រាទី ៩ កថាខ័ណ្ឌទី ២ និងទី ៣ ហើយឧបសម្ព័ន្ធសំរាប់ពិធីសារណាមួយត្រូវតែស្នើឡើង និងអនុម័ត យោងតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រាទី ៩ កថាខ័ណ្ឌទី ២ និងទី ៤ ។

ខ. សមាជិកណាមួយដែលមិនអាចអនុម័តឧបសម្ព័ន្ធបន្ថែមរបស់អនុសញ្ញានេះ ឬឧបសម្ព័ន្ធរបស់ពិធីសារណាមួយដែលខ្លួនជាសមាជិក ត្រូវតែជូនដំណឹងជាលាយល័ក្ខអក្សរដល់កន្លែងតំកល់ទុក ក្នុងរយៈពេលប្រាំមួយខែចាប់ពីពេលដែលកន្លែងតំកល់ទុកផ្តល់ពត៌មានស្តីពីការទទួលយកឧបសម្ព័ន្ធនោះ ។ កន្លែងតំកល់ទុកត្រូវតែជូនដំណឹងជាលាយល័ក្ខអក្សរជាបន្ទាន់ ដល់សមាជិកទាំងអស់ ។ នៅពេលណាក៏បាន សមាជិកណាមួយអាចទទួលយកឧបសម្ព័ន្ធ ជំនួសឱ្យការការប្រកាសបដិសេធពីពេលមុន ហើយបន្ទាប់មក ឧបសម្ព័ន្ធនោះត្រូវចូលជាធរមានសំរាប់សមាជិកនោះ ។

គ. ក្រោយរយៈពេលប្រាំមួយខែ គិតចាប់ពីពេលដែលកន្លែងតំកល់ទុកចែកផ្សាយនូវសេចក្តីជូនដំណឹង ឧបសម្ព័ន្ធនឹងត្រូវចូលជាធរមានសំរាប់សមាជិកទាំងអស់នៃអនុសញ្ញានេះ ឬនៃពិធីសារពាក់ព័ន្ធ ហើយដែលភាគីទាំងនោះមិនបានធ្វើសេចក្តីជូនដំណឹង យោងតាមខដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌ "ខ" ខាងលើ ។

៣. សំណើ ការទទួលយក និងការចូលជាធរមាននៃវិសោធនកម្មលើឧបសម្ព័ន្ធរបស់អនុសញ្ញានេះ ឬរបស់ពិធីសារណាមួយ ត្រូវតែអនុវត្តដោយអនុលោមទៅតាមនីតិវិធីដូចគ្នាទៅនឹងសំណើ ការទទួលយក និងការចូលជាធរមាននៃឧបសម្ព័ន្ធរបស់អនុសញ្ញានេះ ឬឧបសម្ព័ន្ធរបស់ពិធីសារណាមួយ ។ វិសោធនកម្ម និងឧបសម្ព័ន្ធទាំងនេះត្រូវតែសង្កត់ធ្ងន់លើកិច្ចការវិទ្យាសាស្ត្រ និងបច្ចេកទេស ។

៤. ប្រសិនបើឧបសម្ព័ន្ធបន្ថែម ឬវិសោធនកម្មរបស់ឧបសម្ព័ន្ធ បណ្តាលឱ្យមានវិសោធនកម្មលើអនុសញ្ញានេះ ឬលើពិធីសារណាមួយ នោះឧបសម្ព័ន្ធបន្ថែម ឬវិសោធនកម្មរបស់ឧបសម្ព័ន្ធខាងលើ មិនអាចចូលជាធរមានបានទេ ប្រសិនបើវិសោធនកម្មលើអនុសញ្ញានេះ ឬលើពិធីសារពាក់ព័ន្ធមិនទាន់ចូលជាធរមាន ។

## មាត្រា ១១
## ការដោះស្រាយវិវាទ

១. នៅក្នុងករណីដែលមានវិវាទរវាងសមាជិកអនុសញ្ញា ស្តីពីការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ សមាជិកទាំងនោះត្រូវស្វែងរកដំណោះស្រាយ តាមរយៈការចរចារ ។

២. ប្រសិនបើសមាជិកទាំងនោះមិនអាចឈានទៅដល់កិច្ចព្រមព្រៀងបានតាមរយៈការចរចារ នោះគេអាចស្វែងរករួមគ្នានូវការសំរុះសំរួល ដោយភាគីទីបី ។

៣. នៅពេលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលណាមួយក្រោយពីនេះ ប្រទេស ឬអង្គការសេដ្ឋកិច្ចរួមក្នុងតំបន់ អាចប្រកាសជាលាយល័ក្ខអក្សរ ដល់កន្លែងតំកល់ទុក ថាចំពោះវិវាទដែលមិនអាចដោះស្រាយតាមរយៈវិធីដូចមានចែងក្នុងកថាខ័ណ្ឌទី ១ និងទី ២ ខាងលើ ខ្លួននឹងទទួលយកនូវមធ្យោបាយដោះស្រាយវិវាទមួយ ឬទាំងពីរខាងក្រោម យោងតាមការចាំបាច់ :

ក. ការសំរុះសំរួល យោងតាមនីតិវិធីដែលនឹងត្រូវអនុម័តដោយអង្គសន្និបាតរបស់ភាគី នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី ១ របស់ខ្លួន ។

ខ. ការដាក់ក្តីវិវាទជូនទៅតុលាការអន្តរជាតិ ។

៤. ប្រសិនបើ យោងតាមកថាខ័ណ្ឌទី ៣ ខាងលើ ភាគីវិវាទពុំទទួលយកនូវនីតិវិធីដូចគ្នាណាមួយ នោះក្តីវិវាទត្រូវដាក់ជូនទៅ conciliation យោងតាមកថាខ័ណ្ឌទី ៥ ខាងក្រោម ប្រសិនបើភាគីទាំងនោះពុំបានឯកភាពដោយរបៀបណាមួយផ្សេងទៀត ។

៥. គណកម្មការ conciliation ត្រូវរៀបចំឡើង យោងតាមសំណើរបស់ភាគីវិវាទណាមួយ ។ ភាគីពាក់ព័ន្ធនីមួយៗតែងតាំងចំនួនសមាជិកនៃគណៈកម្មការនេះស្មើគ្នា ហើយប្រធានមួយរូបត្រូវជ្រើសរើសឡើងដោយសមាជិកទាំងអស់ដែលតែងតាំងដោយភាគីនីមួយៗ ។ គណកម្មាធិការនេះត្រូវផ្តល់នូវអនុសាសន៍ចុងក្រោយ ដែលភាគីទាំងអស់ត្រូវគោរពតាម ។

៦. ឧទាំងឡាយនៃមាត្រានេះមានប្រសិទ្ធិភាពសំរាប់ពិធីសារទាំងអស់ លើកលែងតែមានចែងដោយឡែកនៅក្នុងពិធីសារនោះ ។

## មាត្រា ១២
## ហត្ថលេខា

អនុសញ្ញានេះត្រូវចំហសំរាប់ចុះហត្ថលេខា នៅក្រសួងការបរទេសសហព័ន្ធរបស់សាធារណរដ្ឋអូទ្រីស នៅទីក្រុងវីយែន ចាប់ពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៥ ដល់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៨៥ និងនៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ នៅទីក្រុងញូយ៉ក ចាប់ពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៨៥ ដល់ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៨៦ ។

## មាត្រា ១៣
## ការផ្តល់សច្ចាប័នការទទួលយកនិងការអនុម័ត

១. អនុសញ្ញានេះ និងពិធីសារណាមួយ គឺជាកម្មវត្ថុសំរាប់ការផ្តល់សច្ចាប័ន ការទទួលយក និងការអនុម័ត ដោយរដ្ឋនានា ឬដោយអង្គការសេដ្ឋកិច្ចតំបន់ ។

២. អង្គការណាមួយ ដែលមានចែងនៅក្នុងកថាខ័ណ្ឌទីមួយខាងលើ ហើយដែលក្លាយជាសមាជិកនៃអនុសញ្ញានេះ ឬនៃពិធីសារណាមួយ ដោយពុំមានប្រទេសជាសមាជិករបស់ខ្លួនជាភាគីសមាជិករបស់អនុសញ្ញាឬពិធីសារនោះ ត្រូវមានកាតព្វកិច្ចទាំងអស់ នៅក្រោមអនុសញ្ញា ឬពិធីសារនោះ ។ នៅក្នុងករណីដែលមានសមាជិកមួយ ឬច្រើនរបស់អង្គការ ជាភាគីសមាជិករបស់អនុសញ្ញា ឬពិធីសារពាក់ព័ន្ធ អង្គការនោះ និងសមាជិករបស់ខ្លួនត្រូវធ្វើការសំរេចស្តីពីការទទួលខុសត្រូវរបស់ខ្លួន លើការអនុវត្តកាតព្វកិច្ចខ្លួន ក្រោមអនុសញ្ញា ឬពិធីសារនោះ ។ នៅក្នុងករណីនេះ អង្គការ និងប្រទេសជាសមាជិករបស់អង្គការនេះ ពុំត្រូវបានផ្តល់សិទ្ធិនានា នៅក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធនៅក្នុងពេលតែមួយឡើយ ។

៣. នៅក្នុងឧបករណ៍ផ្តល់សច្ចាប័ន ទទួលយក ឬអនុម័តរបស់ខ្លួន អង្គការទាំងឡាយដែលមាននិយាយក្នុងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវប្រកាសស្តីពីទំហំនៃសមត្ថកិច្ចរបស់ខ្លួន ពាក់ព័ន្ធនឹងកិច្ចការក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះក៏ត្រូវផ្តល់ពត៌មានដល់កន្លែងតំកល់ទុក ស្តីពីការកែប្រែសំខាន់ណាមួយ លើទំហំនៃសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ១៤
## ការចូលជាសមាជិក

១. អនុសញ្ញានេះ និងពិធីសារណាមួយ ត្រូវបើកចំហសំរាប់ការចូលជាសមាជិកដោយប្រទេសនានា និងអង្គការសេដ្ឋកិច្ចតំបន់ ចាប់តាំងពីថ្ងៃដែលអនុសញ្ញា ឬពិធីសារនោះត្រូវបិទបញ្ឈប់ការចុះហត្ថលេខា ។ ឧបករណ៍នៃការចូលជាសមាជិកត្រូវទុកនៅកន្លែងតំកល់ទុក ។

២. នៅក្នុងឧបករណ៍នៃការចូលជាសមាជិករបស់ខ្លួន អង្គការទាំងឡាយដែលមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវប្រកាសស្តីពីទំហំនៃសមត្ថកិច្ចរបស់ខ្លួន ពាក់ព័ន្ធនឹងកិច្ចការក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះ ក៏ត្រូវផ្តល់ពត៌មានដល់កន្លែងតំកល់ទុក ស្តីពីការកែប្រែសំខាន់ណាមួយ លើទំហំនៃសមត្ថកិច្ចរបស់ខ្លួន ។

៣. ខទាំងឡាយនៃកថាខ័ណ្ឌទី ២ របស់មាត្រាទី ១៣ ត្រូវអនុវត្តសំរាប់អង្គការសេដ្ឋកិច្ចតំបន់ ដែលចូលជាសមាជិកជាមួយនឹងអនុសញ្ញា ឬពិធីសារណាមួយ ។

## មាត្រា ១៥
## សិទ្ធិបោះឆ្នោត

១. សមាជិកនៃអនុសញ្ញានេះ ឬពិធីសារណាមួយ ត្រូវមានសំលេងមួយ ។

២. លើកលែងតែឬចមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើ នៅក្នុងកិច្ចការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន អង្គការសេដ្ឋកិច្ចតំបន់ ត្រូវបញ្ចេញសិទ្ធិបោះឆ្នោត ដោយមានចំនួនសំលេងស្មើនឹងចំនួនប្រទេសជាសមាជិករបស់ខ្លួន ហើយដែលជាសមាជិករបស់អនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះត្រូវចូលរួមបោះឆ្នោត ប្រសិនបើប្រទេសជាសមាជិករបស់ខ្លួនបញ្ចេញសិទ្ធិបោះឆ្នោតរបស់ខ្លួន និងផ្ទុយមកវិញ ។

## មាត្រា ១៦
## ទំនាក់ទំនងរវាងអនុសញ្ញានិងពិធីសារនានារបស់វា

១. ប្រទេសមួយ ឬអង្គការសេដ្ឋកិច្ចតំបន់មួយពុំអាចជាសមាជិករបស់ពិធីសារបានទេ ប្រសិនបើគេពុំមែនជាសមាជិករបស់អនុសញ្ញា ឬក៏អាចជាសមាជិករបស់ពិធីសារ និងអនុសញ្ញាក្នុងពេលតែមួយ ។

២. សេចក្តីសំរេចដែលពាក់ព័ន្ធនឹងពិធីសារត្រូវតែធ្វើឡើង ដោយសមាជិករបស់ពិធីសារនោះតែប៉ុណ្ណោះ ។

## មាត្រា ១៧
## ការចូលជាធរមាន

១. អនុសញ្ញានេះត្រូវចូលជាធរមាន នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកនូវឧបករណ៍ទីម្ភៃនៃការផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក ។

២. ពិធីសារណាមួយ លើកលែងតែមានចែងដោយឡែកនៅក្នុងពិធីសារនោះ ត្រូវចូលជាធរមាន នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកនូវឧបករណ៍ទីដប់មួយនៃការផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក ។

៣. សំរាប់សមាជិកណា ដែលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកលើអនុសញ្ញានេះ ក្រោយពីការតំកល់ទុកនូវឧបករណ៍ទីម្ភៃនៃការផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក អនុសញ្ញានេះត្រូវចូលជា

ធរមាន នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកនូវឧបករណ៍ផ្តល់ សច្ចាប័ន ទទួលយក អនុម័ត ឬ ចូលជាសមាជិក របស់សមាជិកនោះ ។

៤. ពិធីសារណាមួយ លើកលែងតែមានចែងដោយឡែកនៅក្នុងពិធីសារនោះ ត្រូវចូលជាធរមាន សំរាប់សមាជិកដែលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកលើពិធីសារនោះ ក្រោយពេលដែលពិធីសារនោះចូលជាធរមាន អនុលោមតាមកថាខ័ណ្ឌទី ២ ខាងលើ នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទដែលសមាជិកនោះដាក់តំកល់ទុកនូវឧបករណ៍ផ្តល់ សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិករបស់ខ្លួន ឬនៅថ្ងៃដែលអនុសញ្ញាចូលជាធរមានសំរាប់សមាជិកនោះ ។ ចំពោះកាលបរិច្ឆេទទាំងពីរនេះ ត្រូវយកតាមកាលបរិច្ឆេទណាដែលក្រោយគេ ។

៥. សំរាប់កថាខ័ណ្ឌទី ១ និងទី ២ ខាងលើ ឧបករណ៍ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិករបស់អង្គការសេដ្ឋកិច្ចតំបន់ណាមួយ ពុំត្រូវចាត់ទុកថាជាឧបករណ៍បន្ថែមទៀត សំរាប់សមាជិករបស់អង្គការនោះឡើយ ។

## មាត្រា ១៨
## ខមាក់លក្ខខណ្ឌ

ពុំមានខដាក់លក្ខខណ្ឌណាមួយអាចត្រូវធ្វើសំរាប់អនុសញ្ញានេះទេ ។

## មាត្រា ១៩
## ការលាចេញ

១. សមាជិកណាមួយអាចលាចេញពីអនុសញ្ញា តាមរយៈការជូនដំណឹងជាលាយល័ក្ខអក្សរដល់កន្លែងតំកល់ទុក នៅពេលណាមួយក៏បាន ក្រោយរយៈពេលបួនឆ្នាំ គិតចាប់ពីពេលដែលអនុសញ្ញានេះចូលជាធរមានសំរាប់ភាគីនោះ ។

២. លើកលែងតែក្នុងករណីដែលមានចែងដោយឡែកនៅក្នុងពិធីសារណាមួយ ភាគីណាមួយអាចលាចេញពីពិធីសារណាមួយ តាមរយៈការជូនដំណឹងជាលាយល័ក្ខអក្សរដល់កន្លែងតំកល់ទុក នៅពេលណាមួយក៏បាន ក្រោយរយៈពេលបួនឆ្នាំ គិតចាប់ពីពេលដែលអនុសញ្ញានេះចូលជាធរមាន សំរាប់ភាគីនោះ ។

៣. ការលាចេញទាំងនេះត្រូវចូលជាធរមាន ក្រោយរយៈពេលមួយឆ្នាំ គិតចាប់ពីពេលដែលកន្លែងតំកល់ទុកបានទទួលពាក្យសុំលាលែង ឬក៏នៅពេលក្រោយពីនេះទៀត ដែលអាចមានចែងដោយឡែកនៅក្នុងលិខិតជូនដំណឹងស្តីពីការលាចេញ ។

៤. សមាជិកណាមួយដែលលាចេញពីអនុសញ្ញានេះ ត្រូវបានចាត់ទុកថា លាលែងចេញពីពិធីសារទាំងឡាយដែលខ្លួនជាសមាជិក ។

## មាត្រា ២០
## កន្លែងតំកល់ទុក

១. អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ត្រូវទទួលមុខងារជាអ្នកតំកល់ទុកនៃអនុសញ្ញានេះ និងពិធីសារនានា ។

២. កន្លែងតំកល់ទុកត្រូវផ្តល់ពត៌មានខាងក្រោម ជូនដល់សមាជិកនានា :

ក. ការចុះហត្ថលេខាលើអនុសញ្ញានេះ និងលើពិធីសារណាមួយ និងការតំកល់ទុកនូវឧបករណ៍ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក យោងតាមមាត្រា ១៣ និង ១៤ ។

ខ. កាលបរិច្ឆេទដែលអនុសញ្ញា ឬពិធីសារណាមួយចូលជាធរមាន យោងតាមមាត្រា ១៧ ។

គ. លិខិតជូនដំណឹងស្តីពីការលាចេញ ដែលធ្វើឡើងយោងតាមមាត្រាទី ១៩ ។

ឃ. វិសោធនកម្ម ដែលអនុម័តសំរាប់អនុសញ្ញា ឬពិធីសារណាមួយ ការទទួលយកវិសោធនកម្មនោះដោយ

សមាជិកនានា និងកាលបរិច្ឆេទនៃការចូលជាធរមាន យោងតាមជំពូក ៩ ។

ង. របាយការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងការយល់ព្រម នឹងការអនុម័តលើឧបសម្ព័ន្ធនានា និងលើវិសោធនកម្មនៃឧបសម្ព័ន្ធ អនុលោមទៅតាមមាត្រាទី ១០ ។

ច. សេចក្តីជូនដំណឹងរបស់អង្គការសេដ្ឋកិច្ចតំបន់ ស្តីពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងទៅនឹងកិច្ចការនានា ដែលកំណត់ដោយអនុសញ្ញានេះ និងពិធីសារនានា ព្រមទាំងការកែប្រែណាមួយ ។

ឆ. សេចក្តីប្រកាស ដែលធ្វើឡើងយោងតាមជំពូក ១១ កថាខណ្ឌទី ៣ ។

## មាត្រា ២១
## អត្ថបទច្បាប់ដើម

ច្បាប់ដើមនៃអនុសញ្ញានេះ មានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្បាញ មានតម្លៃស្មើគ្នា ហើយ ត្រូវតំកល់ទុកនៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ។

អនុសញ្ញានេះត្រូវបានចុះហត្ថលេខាដោយតំណាងដែលមានសិទ្ធិពេញលេញ ។

ធ្វើនៅទីក្រុងវីយែន ថ្ងៃទី ២២ ខែមីនា ឆ្នាំ ១៩៨៥ ។

## ឧបសម្ព័ន្ធ ១

## ការស្រាវជ្រាវនិងការសង្កេតតាមដានជាប្រចាំ

១. សមាជិកទាំងអស់របស់អនុសញ្ញានេះ ទទួលស្គាល់ថា បញ្ហាវិទ្យាសាស្ត្រសំខាន់ៗគឺ :

ក. ការកែប្រែស្រទាប់អូសូន ដែលនាំឱ្យមានការប្រែប្រួលនូវបរិមាណរំភាយកាំរស្មីស្វាយអុលត្រារបស់ព្រះអាទិត្យ មានឥទ្ធិពលជីវសាស្ត្រ (UV-B) ដែលចាំងមកដល់ផ្ទៃផែនដី ព្រមទាំងផលវិបាកដែលអាចកើតមានដល់សុខភាពមនុស្ស ដល់សារពាង្គកាយ ស្ថានប្រព័ន្ធ និងរូបធាតុនានាដែលមានប្រយោជន៍សំរាប់មនុស្សជាតិ ។

ខ. ការកែប្រែនូវរបាយអូសូនតាមបន្ទាត់ឈរ ដែលអាចផ្លាស់ប្តូររចនាសម្ព័ន្ធរបស់សីតុណ្ហភាពបរិយាកាស និង ផលវិបាកដែលអាចកើតមានដល់ធាតុអាកាស និងអាកាសធាតុ ។

២. យោងតាមមាត្រាទី ៣ សមាជិកទាំងអស់របស់អនុសញ្ញានេះត្រូវធ្វើសហប្រតិបត្តិការ ក្នុងការដឹកនាំការស្រាវជ្រាវ និងការសង្កេតតាមដានជាប្រចាំ និងក្នុងការរៀបចំអនុសាសន៍នានា សំរាប់កិច្ចការស្រាវជ្រាវ និងសង្កេតតាមដាននាពេលអនាគត នៅក្នុងវិស័យទាំងឡាយ ដូចជា :

ក. ការស្រាវជ្រាវលើផ្នែករូបសាស្ត្រ និងគីមីរបស់បរិយាកាស

(១) គំរូជាទ្រឹស្តីយ៉ាងពេញលេញ : ការរៀបចំគំរូបន្តទៀត ដែលពិនិត្យលើអន្តរកម្មរវាងដំណើរការរំភាយរស្មី ឌីណាមិច និងគីមី, សិក្សាពីឥទ្ធិពល នៅពេលតែមួយ របស់ប្រភេទដែលកើតឡើងដោយធម្មជាតិ និងប្រភេទដែលមនុស្សបង្កើត ទៅលើអូសូនបរិយាកាស, បំណកស្រាយសំណុំទិន្នន័យផ្កាយរណប ឬមិនមែនផ្កាយរណប ដែលវាស់វែងបាន, វាយតំលៃលើនិន្នាការរបស់ប៉ារ៉ាម៉ែតបរិយាកាស និងរូបភូគព្ភសាស្ត្រ, និង ការរៀបចំវិធីសាស្ត្រសំរាប់កំណត់ទំនាក់ទំនងរវាងការប្រែប្រួលនៅក្នុងប៉ារ៉ាម៉ែតទាំងនេះ ជាមួយនឹងមូលហេតុដោយឡែកនានា ។

(២) ការសិក្សាក្នុងមន្ទីរពិសោធន៍លើ : rate coefficients, absorption cross-sections និងយន្តការនៃដំណើរប្រព្រឹត្តិគីមី និងផូតូគីមីរបស់មណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់, ទិន្នន័យបានមកពីការវិភាគស្បិច សំរាប់គាំទ្រការវាស់វែងនៅនឹងកន្លែងនៅគ្រប់តំបន់ស្បិចពាក់ព័ន្ធ ។

(៣) ការវាស់វែងនៅនឹងកន្លែង : កំហាប់ និងភ្នំចរបស់ប្រភពឧស្ម័នសំខាន់ៗដែលមានប្រភពពីធម្មជាតិ និងពីមនុស្ស, ការសិក្សាពីឌីណាមិចបរិយាកាស, ការវាស់វែងក្នុងពេលតែមួយលើ photochemically-related species down to the planetary boundary layer ដោយប្រើឧបករណ៍នៅនឹងកន្លែង ឬពីចំងាយ, ការប្រៀបធៀបគ្នាទៅវិញទៅមកលើ sensors ផ្សេងៗគ្នា ដោយរួមទាំង coordinated correlative measurements for satellite instrumentation, three-dimensional fields of key atmospheric trace constituents ភ្នំចស្បិចពន្លឺព្រះអាទិត្យ និងប៉ារ៉ាម៉ែតឧតុនិយម ។

(៤) ការបង្កើតឧបករណ៍ ដូចជា satellite and non-satellite sensors for atmospheric trace constituents ភ្នំចព្រះអាទិត្យ និងប៉ារ៉ាម៉ែតឧតុនិយម ។

ខ. ការសិក្សាស្រាវជ្រាវពីឥទ្ធិពលលើសុខភាព ជីវសាស្ត្រ និងការបំបែកធាតុដោយរស្មី (photodegradation)

(១) ទំនាក់ទំនងរវាងការសំដិលត្រូវរបស់មនុស្សទៅនឹងកាំរស្មីព្រះអាទិត្យដែលមើលឃើញ និងកាំរស្មីស្វាយអុលត្រា និង (ក) ការវិវឌ្ឍន៍មហារីកស្បែកប្រភេទ non-melanoma និង melanoma និង (ខ) ផលប៉ះពាល់លើ immunological system ។

(២) ផលប៉ះពាល់នៃកាំរស្មី UV-B រួមទាំងជំហានរលក ទៅលើ : (ក) ដំណាំកសិកម្ម ព្រៃឈើ និងស្ថានប្រព័ន្ធដីគោក និង (ខ) បណ្តាញអាហារក្នុងទឹក និងជលផល ព្រមទាំងការរំខានដល់ការផលិតអុកស៊ីសែនដោយបួងតុងរុក្ខជាតិ ។

(៣) យន្តការដែលកាំរស្មី UV-B មានអំពើលើរូបធាតុជីវៈ ប្រភេទ និងស្ថានប្រព័ន្ធ រួមមាន : ទំនាក់ទំនងរវាងកំរិតស្រូប អត្រាកំរិតស្រូប និងប្រតិកម្មតប, photorepair បន្សាំ និងការការពារ ។

(៤) ការសិក្សាពី biological action spectra និង ប្រតិកម្មឆ្លើយតបរបស់ស្បិច ដោយប្រើកាំរស្មីប៉ូលីក្រូម៉ាទិច ដើម្បីដាក់បញ្ចូលនូវទំនាក់ទំនងដែលអាចមានរបស់តំបន់មានជំហានរលកផ្សេងៗគ្នា ។

(៥) ឥទ្ធិពលនៃកាំរស្មី UV-B ទៅលើ : ភាពលូតលាស់ និងសកម្មភាពរបស់ប្រភេទជីវសាស្ត្រ ដែលមានសារៈសំខាន់សំរាប់តុល្យភាពមណ្ឌលជីវៈ ដំណើរការជំរុញនានា ដូចជារស្មីសំយោគ និងជីវសំយោគ ។

(៦) ឥទ្ធិពលនៃកាំរស្មី UV-B ទៅលើការបំបែកធាតុដោយរស្មីនៃសារធាតុបំពុល សារធាតុគីមីកសិកម្ម និងរូបធាតុផ្សេងទៀត ។

គ. ការស្រាវជ្រាវស្ដីពីឥទ្ធិពលទៅលើអាកាសធាតុ

(១) ការសិក្សាបែបទ្រឹស្ដី និងដោយសង្កេតលើឥទ្ធិពលរំភាយរស្មីរបស់អូសូន និងប្រភេទឧស្ម័នមួយចំនួនទៀត និងលើផលប៉ះពាល់ដល់ល័ក្ខខ័ណ្ឌអាកាសធាតុ ដូចជាសីតុណ្ហភាពផ្ទៃដីនិងផ្ទៃសមុទ្រ របបកំណកអាកាស ការផ្លាស់ប្ដូររវាងមណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់ ។

(២) ការស្រាវជ្រាវស្ដីពីឥទ្ធិពលនៃផលប៉ះពាល់អាកាសធាតុទៅលើផ្នែកផ្សេងៗនៃសកម្មភាពមនុស្ស ។

ឃ. ការសង្កេតតាមដានជាប្រចាំ

(១) ស្ថានភាពនៃស្រទាប់អូសូន (ពោលគឺការប្រែប្រួលក្នុងកាល និងលំហ នូវសមាសភាពសរុប និងរបាយតាមបន្ទាត់ឈរ) តាមរយៈការធ្វើប្រព័ន្ធសង្កេតពិនិត្យអូសូនពិភពលោក ដោយឈរលើការដាក់បញ្ចូលគ្នានូវប្រព័ន្ធផ្កាយរណប និងប្រព័ន្ធមានមូលដ្ឋានលើផ្ទៃដី ដែលដំណើរការ ។

(២) កំហាប់នៅក្នុងមណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់ នៃឧស្ម័នជាប្រភពនៃ HO NO $ClO_x$ និងអំបូរកាបូន ។

(៣) សីតុណ្ហភាពចាប់ពីផ្ទៃដី ទៅដល់បរិយាកាស ដោយប្រើប្រព័ន្ធផ្កាយរណប និងប្រព័ន្ធមានមូលដ្ឋានលើផ្ទៃដី ។

(៤) ភ្លុចកាំរស្មីព្រះអាទិត្យ wavelength-resolved ដែលចាំងមកដល់បរិយាកាស និងរំភាយកំដៅដែលផ្ទាតចេញពីបរិយាកាសវិញ ដោយប្រើការវាស់វែងតាមផ្កាយរណប ។

(៥) ភ្លុចកាំរស្មីព្រះអាទិត្យ wavelength-resolved ដែលចាំងមកដល់ផ្ទៃផែនដី ក្នុងទំរង់ជាកាំរស្មីស្វាយអ៊ុលត្រាដែលមានឥទ្ធិពលជីវសាស្ត្រ (UV-B) ។

(៦) លក្ខណៈរបស់អាអេរ៉ូសុល និងរបាយរបស់វា ចាប់ពីផ្ទៃផែនដី រហូតដល់មេសូស្វែ ដោយប្រើប្រព័ន្ធដាក់នៅលើផ្ទៃដី យន្តហោះ ឬផ្កាយរណប ។

(៧) បំរែបំរួលគីមីសំខាន់ៗ តាមរយៈការទ្រទ្រង់ដល់កម្មវិធីវាស់វែងឧតុនិយមវិទ្យានៅលើផ្ទៃដីដែលមានគុណភាពខ្ពស់ ។

(៨) Trace species សីតុណ្ហភាព ភ្លុចកាំរស្មីព្រះអាទិត្យ និងអាអេរ៉ូសូល ដោយប្រើវិធីដែលត្រូវបានកែលំអសំរាប់វិភាគទិន្នន័យពិភពលោក ។

៣. សមាជិកនៃអនុសញ្ញាទាំងអស់ត្រូវសហការ ដោយយកចិត្តទុកដាក់លើតំរូវការដោយឡែករបស់ប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការបណ្ដុះបណ្ដាលវិទ្យាសាស្ត្រ និងបច្ចេកទេសសមស្រប ដែលចាំបាច់សំរាប់ចូលរួមក្នុងការស្រាវជ្រាវ និងសង្កេតតាមដានជាប្រចាំ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនេះ ។ ត្រូវផ្ដោតអារម្មណ៍ជាពិសេសលើការធ្វើឱ្យត្រូវខ្នាតគ្នានៃឧបករណ៍សំរាប់សង្កេតតាមដាន និងវិធីនានា សំដៅបង្កើតសំណុំទិន្នន័យវិទ្យាសាស្ត្រដែលអាចប្រៀបធៀបគ្នាបាន ឬដែលមានស្តង់ដាដូចគ្នា ។

៤. សារធាតុគីមីខាងក្រោម ដែលមានប្រភពធម្មជាតិ ឬប្រភពពីមនុស្ស ហើយដែលពុំត្រូវបានរៀបដាក់តាមលំដាប់អាទិភាព ត្រូវបានគេយល់ស្របថា មានសក្តានុពលភាពក្នុងការកែប្រែលក្ខណៈគីមី និងលក្ខណៈរូបរបស់ស្រទាប់អូសូន :

ក. សារធាតុកាបូន :

(១) កាបូនម៉ូណូអុកស៊ីត (CO)

កាបូនម៉ូណូអុកស៊ីតមានប្រភពសំខាន់ពីធម្មជាតិ និងពីមនុស្ស ហើយគេគិតថាចូលរួមដោយផ្ទាល់នៅក្នុងដំណើរផ្លូវគីមីក្នុងមណ្ឌលអាកាសរចល់ និងចូលរួមដោយប្រយោលនៅក្នុងដំណើរផ្លូវគីមីក្នុងមណ្ឌលអាកាសស្ងប់ ។

(២) កាបូនឌីអុកស៊ីត ($CO_2$)

កាបូនឌីអុកស៊ីតមានប្រភពសំខាន់ពីធម្មជាតិ និងពីមនុស្ស ហើយមានឥទ្ធិពលលើអូសូនរបស់មណ្ឌលអាកាសស្ងប់ តាមរយៈអំពើទៅលើរចនាសម្ព័ន្ធកំដៅរបស់បរិយាកាស ។

(៣) មេតាន ($CH_4$)

មេតានមានប្រភពសំខាន់ពីធម្មជាតិផង និងពីមនុស្សផង ហើយមានឥទ្ធិពលលើអូសូននៅក្នុងមណ្ឌលអាកាសរចល់ និងក្នុងមណ្ឌលអាកាសស្ងប់ ។

(៤) សារធាតុអ៊ីដ្រូកាបូក្រៅពីមេតាន

សារធាតុអ៊ីដ្រូកាបូក្រៅពីមេតាន ដែលរួមមានសារធាតុគីមីជាច្រើន មានប្រភពពីធម្មជាតិ និងពីមនុស្ស ហើយចូលរួមដោយផ្ទាល់ក្នុងដំណើរផ្លូវគីមីនៅមណ្ឌលអាកាសរចល់ និងដោយប្រយោលក្នុងដំណើរផ្លូវគីមីនៅមណ្ឌលអាកាសស្ងប់ ។

ខ. សារធាតុអាសូត

(១) នីអាសូតម៉ូណូអុកស៊ីត ($N_2O$)

$N_2O$ មានប្រភពចំបងពីធម្មជាតិ ប៉ុន្តែប្រភពពីមនុស្សកាន់តែកើនឡើងជាលំដាប់ ។ នីអាសូតម៉ូណូអុកស៊ីតជាប្រភពបឋមនៃអាសូតអុកស៊ីត ($NO_x$) ក្នុងមណ្ឌលអាកាសស្ងប់ ដែលមាននាទីយ៉ាងសំខាន់នៅក្នុងការត្រួតពិនិត្យភាពសំបូរហូរហៀរនៃអូសូនក្នុងមណ្ឌលអាកាសស្ងប់ ។

(២) អាសូតអុកស៊ីត ($NO_x$)

ប្រភព $NO_x$ នៅកំពស់ផ្ទៃដីមាននាទីសំខាន់ផ្ទាល់ក្នុងដំណើរគីមីនៅមណ្ឌលអាកាសរចល់ និងមាននាទីប្រយោលក្នុងដំណើរគីមីនៅមណ្ឌលអាកាសស្ងប់ ហើយការបញ្ចេញ $NO_x$ នៅក្បែរស្រទាប់ត្រូប៉ូប៉ោស អាចបណ្តាលឱ្យមានការប្រែប្រួលដោយផ្ទាល់នៃអូសូនមណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់ ។

គ. សារធាតុក្លរ

(១) អាល់កានរងអាឡូសែនកម្ពេញ ដូចជា $CCl_4$, $CFCl_3$ (CFC-11), $CF_2Cl_2$ (CFC-12), $C_2F_3Cl_3$ (CFC-113), $C_2F_4Cl_2$ (CFC-114)

អាល់កានអាឡូសែនពេញមានប្រភពពីធម្មជាតិ ហើយដើរតួជាប្រភពនៃ $ClO_x$ ដែលមាននាទីយ៉ាងសំខាន់នៅក្នុងដំណើរផ្លូវគីមីនៃអូសូន ជាពិសេសនៅរយៈកំពស់ 30-50 km.

(២) អាល់កានរងអាឡូសែនដោយភាគ ដូចជា $CH_3Cl$, $CHF_2Cl$ (CFC-22), $CH_3CCl_3$, $CHFCl_2$ (CFC-21)

$CH_3Cl$ មានប្រភពពីធម្មជាតិ ហើយអាល់កានរងអាឡូសែនដោយភាគក្រៅពីនេះ ដែលមានរៀបរាប់ខាងលើ មានប្រភពពីមនុស្ស ។ ឧស្ម័នទាំងនេះមាននាទីជាប្រភពនៃ $ClO_x$ នៅក្នុងមណ្ឌលអាកាសស្ងប់ ។

ឃ. សារធាតុប្រូម

អាល់កានរងអាឡូសែនកម្ពេញ ដូចជា $CF_3Br$ ។ ឧស្ម័នទាំងនេះមានប្រភពពីមនុស្ស ហើយមាននាទីជា

ប្រភពនៃ $BrO_x$ ដែលមានអំពើស្រដៀងគ្នាទៅនឹង $ClO_x$ ដែរ ។

ង. សារធាតុអ៊ីដ្រូសែន

(១) អ៊ីដ្រូសែន ($H_2$)

អ៊ីដ្រូសែនមានប្រភពពីធម្មជាតិផង និងពីមនុស្សផង ហើយមាននាទីពុំសូវ សំខាន់នៅក្នុងដំណើរផ្លូវគីមី នៃមណ្ឌលអាកាសស្ទប់ ។

(២) ទឹក ($H_2O$)

ទឹកមានប្រភពពីធម្មជាតិ ហើយមាននាទីយ៉ាងសំខាន់នៅក្នុងដំណើរផ្លូវគីមីក្នុងមណ្ឌលអាកាសចល់ និងក្នុងមណ្ឌលអាកាសស្ទប់ ។ ប្រភពនៅទីងកន្លែងនៃចំហាយទឹកនៅក្នុងមណ្ឌលអាកាសស្ទប់ រួមមានទាំងអុកស៊ីតកម្មនៃមេតាន និងអ៊ីដ្រូសែនក្នុងបរិមាណតិចជាង ។

## ឧបសម្ព័ន្ធ ២

## ការផ្លាស់ប្តូរពត៌មាន

១. សមាជិកទាំងអស់របស់អនុសញ្ញានេះ ទទួលស្គាល់ថា ការប្រមូល និងផ្លាស់ប្តូរពត៌មាន គឺជាមធ្យោបាយយ៉ាងសំខាន់ សំរាប់អនុវត្តទិសដៅនៃអនុសញ្ញានេះ ព្រមទាំងសំរាប់ធានាថា សកម្មភាពនានា ដែលអាចចាត់ធ្វើ មានភាពសមស្រប និងសមធម៌ ។ អាស្រ័យហេតុនេះ សមាជិកទាំងអស់ត្រូវផ្លាស់ប្តូរពត៌មានវិទ្យាសាស្ត្រ បច្ចេកទេស សង្គមកិច្ច សេដ្ឋកិច្ច ជំនួញ ពាណិជ្ជកម្ម និងច្បាប់ ។

២. នៅក្នុងការធ្វើសេចក្តីសំរេចថា តើពត៌មានបែបណាត្រូវប្រមូល និងផ្លាស់ប្តូរ សមាជិកទាំងអស់នៃអនុសញ្ញាត្រូវគិតគូរពីភាពមានប្រយោជន៍របស់ពត៌មាន និងពីតំលៃនៃការប្រមូលយកពត៌មានទាំងនោះ ។ លើសពីនេះ សមាជិកទាំងអស់ទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការនៅក្រោមឧបសម្ព័ន្ធនេះត្រូវតែស្របទៅនឹងច្បាប់របស់ជាតិ បទប្បញ្ញត្តិ និងការអនុវត្តន៍ ដែលពាក់ព័ន្ធនឹងការរក្សាសិទ្ធិ កិច្ចការសំងាត់ពាណិជ្ជកម្ម និងកិច្ចការពារពត៌មានសំងាត់ និងផ្តាច់មុខ ។

៣. ពត៌មានវិទ្យាសាស្ត្រ ដែលរួមមានពត៌មានស្តីពី :

(ក) ការស្រាវជ្រាវដែលកំពុងធ្វើ និងនឹងត្រូវធ្វើ ទាំងរបស់រដ្ឋ ទាំងរបស់ឯកជន សំដៅជំរុញការសំរបសំរួលកម្មវិធីស្រាវជ្រាវ ដើម្បីប្រើប្រាស់ធនធានជាតិ និងអន្តរជាតិដែលមាន ប្រកបដោយប្រសិទ្ធិភាព ។

(ខ) ទិន្នន័យទាក់ទងនឹងការបញ្ចេញឧស្ម័ន ដែលចាំបាច់សំរាប់ការស្រាវជ្រាវ ។

(គ) លទ្ធផលវិទ្យាសាស្ត្រ ដែលបោះពុម្ពផ្សាយនៅក្នុងឯកសារដែលគេពិនិត្យឡើងវិញហើយ ទាក់ទងនឹងចំណេះដឹងស្តីពីរូបសាស្ត្រ និងគីមីរបស់បរិយាកាសផែនដី ព្រមទាំងពីភាពងាយប្រែប្រួល ជាពិសេសស្តីពីស្ថានភាពនៃស្រទាប់អូសូន និងពីឥទ្ធិពលទៅលើសុខភាពមនុស្ស បរិស្ថាន និងអាកាសធាតុ ដែលជាលទ្ធផលនៃការប្រែប្រួលក្នុងកាល នៃបរិមាណសរុប ឬរបាយអូសូនតាមខ្សែឈរ ។

(ឃ) ការវាយតំលៃលើលទ្ធផលនៃការស្រាវជ្រាវ និងអនុសាសន៍នានា សំរាប់ការស្រាវជ្រាវនាពេលអនាគត ។

៤. ពត៌មានបច្ចេកទេស ដែលរួមមានពត៌មានស្តីពី :

(ក) ភាពដែលអាចមាន និងតំលៃនៃសារធាតុគីមីជំនួស និងបច្ចេកវិទ្យាជំនួស សំរាប់កាត់បន្ថយការបញ្ចេញសារធាតុដែលកែប្រែស្រទាប់អូសូន ព្រមទាំងការស្រាវជ្រាវដែលកំពុងដំណើរការ ឬដែលមានគំរោង ។

(ខ) កំរិតព្រំដែន និងភាពប្រថុយប្រថាន ដែលបណ្តាលមកពីការប្រើប្រាស់សារធាតុគីមីជំនួស និងបច្ចេកវិទ្យាជំនួស ។

៥. ពត៌មានសង្គម-សេដ្ឋកិច្ច និងពាណិជ្ជកម្ម ស្តីពីសារធាតុដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី ១ ដែលរួមមានពត៌មានស្តីពី :

(ក) ផលិតកម្ម និងសមត្ថភាពផលិតកម្ម

(ខ) ការប្រើប្រាស់ និងគំរូនៃការប្រើប្រាស់

(គ) ការនាំចេញ និងការនាំចូល

(ឃ) តំលៃ ការប្រថុយប្រថាន និងផលប្រយោជន៍នៃសកម្មភាពមនុស្ស ដែលអាចកែប្រែដោយប្រយោលនូវស្រទាប់អូសូន ព្រមទាំងតំលៃការប្រថុយប្រថាន និងផលប្រយោជន៍នៃផលប៉ះពាល់របស់សកម្មភាពកែតំរូវ ដែលអនុវត្ត ឬលើកយកមកពិនិត្យ សំរាប់គ្រួតពិនិត្យសកម្មភាពទាំងនោះ ។

៦. ពត៌មានផ្នែកច្បាប់ ដែលរួមមាន :

(ក) ច្បាប់របស់ជាតិវិធានការរដ្ឋបាល និងការស្រាវជ្រាវផ្នែកច្បាប់ ដែលទាក់ទងទៅនឹងកិច្ចការពារស្រទាប់អូសូន ។

(ខ) កិច្ចព្រមព្រៀងអន្តរជាតិនានា រួមទាំងកិច្ចព្រមព្រៀងទ្វេភាគី ដែលទាក់ទងទៅនឹងកិច្ចការពារស្រទាប់អូសូន ។

(គ) វិធី និងលក្ខខណ្ឌនានាស្តីពីការចេញអាជ្ញាប័ណ្ណ និងសិទ្ធិផ្តាច់មុខ ដែលទាក់ទងទៅនឹងកិច្ចការពារស្រទាប់អូសូន ។

| | |
|---|---|
| accession | ការសុំចូលជាសមាជិក |
| adoption | ការទទួលយក |
| amendment | វិសោធនកម្ម |
| approval | ការអនុម័ត |
| convention | អនុសញ្ញា |
| model | គំរូ, ម៉ូដែល |
| modification | ការកែប្រែ |
| protocol | ពិធីសារ |
| Party | សមាជិក, ភាគី |